**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១-១១៥ ប្រក

# ប្រកាស
## ស្តីពី
## ការគណនាការប្រាក់ចំពោះឥណទាននៃមីក្រូហិរញ្ញវត្ថុ
## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ០១៩៦/ ២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១១៩៩/ ១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ០៣៩៨/ ៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខ ធ ៧០០-០៥ ប្រក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០០ ស្តីពីការ ផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារ ឯកទេសឥណទានជនបទ
- បានឃើញប្រកាសលេខ ធ ៧០០-០៦ ប្រក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## សំរេច

### ប្រការ ១.

ធនាគារឯកទេសឥណទានជនបទ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី និងបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា អង្គការក្រៅរដ្ឋាភិបាល និងសមាគម ចំណុះច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើការគណនាការប្រាក់លើឥណទានរបស់ខ្លួន អោយបានស្របតាមខ្លឹមសារនៃប្រកាសនេះ ។

### ប្រការ ២.

ការប្រាក់ចំពោះឥណទានដែលបានផ្តល់អោយតាមខ្លឹមសារនៃប្រកាសនេះត្រូវគណនាដោយផ្អែកលើមូលដ្ឋាននៃចំនួនប្រាក់ឥណទានដែលបានផ្តល់ ដោយដកចេញនូវចំនួនប្រាក់ដើមដែលបានសងហើយ បានន័យថា ការប្រាក់លើឥណទានសំរាប់រយៈពេលមួយជាកំណត់ (សប្តាហ៍ ខែ ត្រីមាស ឆ្នាំ តាមករណីនីមួយៗ ) ត្រូវគណនាលើមូលដ្ឋាននៃសមតុល្យឥណទានក្នុងរយៈពេលនោះ ។

**ប្រការ ៣.-**

កិច្ចសន្យារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអតិថិជន ត្រូវមានបង្ហាញតារាងពីការសងរំលោះឥណទាន ។

**ប្រការ ៤.-**

គ្រឹះស្ថានចំណុះច្បាប់ណាដែលមិនគោរពតាមប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៥.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៧.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០១

ទេសាភិបាល

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ

**ចម្លងជូន**

-គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
-ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
-នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

malay/ongoingjob/prakas calculation of interest rate to MFI